**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ០៧៤ - ១៤ ធ.ជ.ប

# សេចក្តីណែនាំ
## ស្តីពី
## ការពិនិត្យប្តូរប្រាក់រៀល មិនគ្រប់លក្ខណៈ

យោងតាមច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ខែមករាឆ្នាំ១៩៩៦ នៅត្រង់ជំពូកទី៩ មាត្រា៥១ និងមាត្រា៥៣។

ដើម្បីរក្សាគុណភាពប្រាក់រៀលក្នុងចរាចរឱ្យបានស្អាត និងធានាផលប្រយោជន៍ជូនប្រជាពលរដ្ឋ ក្នុងការប្រើប្រាស់ និងរក្សាទុកប្រាក់រៀល អគ្គបេឡា សូមកំណត់នូវចំណុចមួយចំនួនសម្រាប់ធ្វើការពិនិត្យ និងប្តូរប្រាក់រៀល មិនគ្រប់លក្ខណៈ ដូចខាងក្រោម ៖

**I- ការកំណត់ប្រាក់រៀលមិនគ្រប់លក្ខណៈ**

ប្រាក់រៀលមិនគ្រប់លក្ខណៈ គឺជាក្រដាសប្រាក់ និងកាស ដែលធនាគារជាតិនៃកម្ពុជាបានបោះផ្សាយកំពុងស្ថិតក្នុងចរាចរ និងមានតម្លៃនីត្យានុកូលក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានបាត់បង់គុណភាពមិនអាចដាក់ឱ្យចរាចរឡើងវិញ ។

ក្រដាសប្រាក់មិនគ្រប់លក្ខណៈ ដូចជា ពុកផុយ ចាស់ ទក់ រហែក ដាច់ដោចច្រើនកន្លែង ជ្រួញ សរសេរ គូរវាស លាបពណ៌ បិទផ្គុំគ្នា បោះត្រា បិទវត្ថុស្អិត ហើរពណ៌ ភ្លើងឆេះ កណ្តៀរកោរកណ្តុរកាត់ បាត់បង់រូបភាពដើម ឬ បោះពុម្ពខុសបច្ចេកទេស ។

កាស មិនគ្រប់លក្ខណៈ ដូចជា សឹករេចរឹល ចោះរន្ធ ស្នឹម ប្រែពណ៌ បាក់ជាបំណែក កាត់ដាច់ផ្នែកណាមួយ ភ្លើងឆេះខូចទ្រង់ទ្រាយ ឬ បោះពុម្ពខុសលក្ខណៈបច្ចេកទេស ។

**II- គោលការណ៍វាយតម្លៃ និងលក្ខខណ្ឌប្តូរប្រាក់រៀលមិនគ្រប់លក្ខណៈ**

**១- គោលការណ៍វាយតម្លៃប្រាក់រៀល មិនគ្រប់លក្ខណៈ**

- ប្រាក់រៀលខូចគុណភាពមកពីអាយុកាលប្រើប្រាស់ ៖ ការធ្វើចរាចរយូរឆ្នាំ
- ប្រាក់រៀលខូចគុណភាពមកពីការថែទាំមិនបានល្អៈការធ្វេសប្រហែសក្នុងការទុកដាក់និងប្រើប្រាស់
- ប្រាក់រៀលខូចគុណភាពមកពីចេតនាបំផ្លាញ ៖ មានបំណាង ឬ ការគ្រោងទុកជាមុន
- ប្រាក់រៀលបោះពុម្ពខុសបច្ចេកទេស ៖ លើស ឬខ្វះលក្ខណៈពិសេសណាមួយ

**២- លក្ខខណ្ឌប្តូរប្រាក់រៀល មិនគ្រប់លក្ខណៈ**

**២-១. ក្រដាសប្រាក់ មិនគ្រប់លក្ខណៈ**

**ក-** ក្រដាសប្រាក់ មិនគ្រប់លក្ខណៈ មកពីអាយុកាលប្រើប្រាស់ ដូចជា ពុកផុយ ចាស់ ទក់ រហែក ហើរពណ៌ ឬដាច់ដោចជាច្រើនកន្លែងប៉ុន្តែរក្សាភាពដើមទំហំ ៧០%នៃក្រដាសប្រាក់ គឺអាចពិនិត្យប្តូរជូនភ្លាមៗ នៅ



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

តាមបញ្ជរបេឡាស្នាក់ការកណ្តាល ឬ បណ្តាសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត តាមតម្រូវការ និងគ្មានការកំណត់បរិមាណ (ឧបសម្ព័ន្ធ ១) ។

**ខ**- ក្រដាសប្រាក់ មិនគ្រប់លក្ខណៈ មកពីការថែទាំមិនបានល្អ

- ក្រដាសប្រាក់ប្រឡាក់ប្រេង ឬ ទឹកខ្មៅតិចតួច ជ្រួញ សរសេរ ឬ គូរវាសតិចតួច ឬ រហែកបាត់បង់ទ្រង់ទ្រាយ ប៉ុន្តែ នៅមានហត្ថលេខាទាំង២ និងលេខមាលាគ្រប់គ្រាន់ ហើយបិទផ្គុំគ្នារក្សាភាពដើមទំហំ៧០%នៃក្រដាសប្រាក់ គឺអាចពិនិត្យប្តូរជូនបាន (ឧបសម្ព័ន្ធ ២) ។

- ក្រដាសប្រាក់រហែកដាច់ជាពីរ ឬច្រើនចំរៀក ហើយយកមកបិទផ្គុំឡើងវិញដោយបំណែកក្រដាសប្រាក់ដើមតែមួយ គឺអាចប្តូរបានតាមតម្លៃដើមនៃសន្លឹកក្រដាសប្រាក់ ។ ក្នុងករណី ក្រដាសប្រាក់បិទផ្គុំឡើងវិញដោយបំណែកក្រដាសប្រាក់ផ្សេងគ្នា គឺមិនអាចប្តូរជូនបានទេ ហើយត្រូវរឹបអូសដោយគ្មានសំណងចំពោះម្ចាស់ឡើយ (ឧបសម្ព័ន្ធ ៣) ។

- ធនាគារជាតិនៃកម្ពុជា បដិសេធមិនប្តូរក្រដាសប្រាក់ដែលបាត់បង់ទំហំពី៣០%ឡើងទៅ ។ ក្រដាសប្រាក់ទាំងនោះត្រូវដកចេញពីចរាចរ ដោយគ្មានសំណងចំពោះម្ចាស់ទេ លើកលែងតែករណីពិសេសដែលធនាគារជាតិនៃកម្ពុជាយល់ព្រមសងមួយផ្នែក ឬទាំងអស់ (ឧបសម្ព័ន្ធ ៤) ។

- ក្រដាសប្រាក់ ប្រៀមទឹក ភ្លើងឆេះ កណ្តៀរកោរកណ្តុរកាត់ (ឧបសម្ព័ន្ធ ៥) ដោយសារការធ្វេសប្រហែស ទុកដាក់មិនបានល្អ ឬ ករណីប្រធានស័ក្តិ ដូចជាខ្យល់ព្យុះ ទឹកជំនន់ លិចកប៉ាល់-ទូក ភ្លើងឆេះផ្ទះ ឆេះអគារ គឺអាចពិនិត្យប្តូរតាមលក្ខខណ្ឌដូចខាងក្រោម ៖

• ក្នុងករណីមានចំនួន ២ ឬ ៣ សន្លឹក ហើយផ្ទៃក្រដាសប្រាក់ខូចតិចតួច ធនាគារជាតិនៃកម្ពុជា អាចពិនិត្យប្តូរជូនភ្លាមតាមតម្លៃដើមនៃសន្លឹកក្រដាសប្រាក់ ។

• ក្នុងករណីមានចំនួនច្រើនសន្លឹក ធនាគារជាតិនៃកម្ពុជាមិនអាចប្តូរជូនបានភ្លាមទេ គឺត្រូវទទួលទុកជាបណ្តោះអាសន្នដើម្បីគណៈកម្មការពិនិត្យនិងសម្រេចលទ្ធភាពអាចប្តូរបានឬមិនបាន ។ ម្ចាស់ប្រាក់ត្រូវបំពេញលិខិតសុំប្តូរប្រាក់មិនគ្រប់លក្ខណៈ នៅនាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡាស្នាក់ការកណ្តាល (ការិយាល័យគ្រប់គ្រងសាច់ប្រាក់) ហើយត្រូវមានលិខិតបញ្ជាក់ពីអាជ្ញាធរ ឬ នគរបាលមូលដ្ឋានច្បាស់លាស់អំពីករណីប្រធានស័ក្តិដែលបានកើតឡើង ។

**គ**- ក្រដាសប្រាក់ មិនគ្រប់លក្ខណៈ មកពីចេតនាបំផ្លាញ

- ក្រដាសប្រាក់ត្រូវបាន ប្រឡាក់ប្រេង ទឹកថ្នាំ សរសេរ ឬ គូរវាស លើព្រះឆាយាល័ក្ខព្រះមហាក្សត្រ គឺត្រូវដកហូតដោយគ្មានសំណងចំពោះម្ចាស់ប្រាក់ឡើយ (ឧបសម្ព័ន្ធ ៦) ។

- ក្រដាសប្រាក់នៅថ្មី តែរហែកដាច់ដោយស្នាមចាប់ហែក ឬ កាត់ផ្តាច់ ហើយមានផ្ទៃនៅសល់លើសពី៧០% និងរក្សាបាននូវហត្ថលេខាទាំង២ និងលេខមាលាគ្រប់គ្រាន់ គឺអាចប្តូរបានតែ ២ ឬ ៣ សន្លឹកប៉ុណ្ណោះ ។ ក្នុងករណី មានចំនួនច្រើនសន្លឹក ធនាគារជាតិនៃកម្ពុជា មិនអាចប្តូរជូនបានភ្លាមទេ គ្រាន់តែទទួលទុកបណ្តោះអាសន្នដើម្បីពិនិត្យ (ឧបសម្ព័ន្ធ ៧) ។

- ក្រដាសប្រាក់ ប្រឡាក់ប្រេងដាមច្រើន ឬ សរសេរគូរវាសក្រវេមក្រវាមធ្វើឱ្យបាត់រូបភាពក្រដាសប្រាក់ពិត ឬ ប្រឡាក់ទឹកថ្នាំគ្រប់ប្រភេទដែលចេញពីឧបករណ៍សុវត្ថិភាពរបស់ម៉ាស៊ីនATM មិនអាចប្តូរជូនបានភ្លាមទេ និងត្រូវដកហូតជាបណ្តោះអាសន្ន ដើម្បីពិនិត្យស្រាវជ្រាវ (ឧបសម្ព័ន្ធ ៨) ។

**ឃ**- ក្រដាសប្រាក់ មិនគ្រប់លក្ខណៈ មកពីខុសបច្ចេកទេសបោះពុម្ព

ក្រដាសប្រាក់ បោះពុម្ពខុសលក្ខណៈបច្ចេកទេសរបស់រោងពុម្ព ធ្វើឱ្យលើសឬខ្វះលក្ខណៈពិសេសណាមួយនៃក្រដាសប្រាក់ ធនាគារជាតិនៃកម្ពុជា ពិនិត្យប្តូរជូនភ្លាម (ឧបសម្ព័ន្ធ ៩) ។

ធនាគារជាតិនៃកម្ពុជានឹងប្តូរជូន ប្រាក់រៀលមិនគ្រប់លក្ខណៈដូចបានរៀបរាប់ខាងលើ លុះត្រាតែជាប្រាក់រៀលពិតប្រាកដ មិនក្លែងក្លាយ ។

**២-២. កាស មិនគ្រប់លក្ខណៈ**

កាស ត្រូវបានសឹករេចរឹល ស្នឹម ស្រអាប់ បោះពុម្ពខុសបច្ចេកទេស ឬ បាត់បង់រូបភាពឬអក្សរ ប៉ុន្តែ រក្សាទ្រង់ទ្រាយដើមទំហំ៧០% នៃកាស គឺអាចពិនិត្យប្តូរជូនភ្លាម ។ ក្នុងករណី កាសត្រូវបានខូចទ្រង់ទ្រាយដោយសារកំដៅ ឬសឹករេចរិលដោយជាតិគីមី ប៉ុន្តែរក្សាទ្រង់ទ្រាយដើមទំហំ៧០% នៃកាស គឺត្រូវពិនិត្យប្តូរជូនតាមភាពជាក់ស្តែង (ឧបសម្ព័ន្ធ ១០) ។

ធនាគារជាតិនៃកម្ពុជាអាចដកហូតដោយគ្មានសំណងនូវកាស ត្រូវបានវាយដំ ឬ ចោះធ្លុះធ្លាយ ឬ ភ្លើងឆេះទន់រៀច បាត់លំនាំដើមដោយប្រការណាក៏ដោយ (ឧបសម្ព័ន្ធ ១១)។

## III- **ការស្រាវជ្រើសប្រាក់រៀល មិនគ្រប់លក្ខណៈ**

នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា និងបណ្តាសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត មានភារកិច្ចធ្វើការរាប់-ស្រាវជ្រើស និងដកយកប្រាក់រៀលមិនគ្រប់លក្ខណៈចេញពីចរាចរ (ឧបសម្ព័ន្ធ ១ ដល់ ១២) ។

## IV- **ការណែនាំអនុវត្ត**

- នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា និងគ្រប់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ត្រូវអនុវត្តសេចក្តីណែនាំនេះ តាមភារកិច្ចរៀងៗខ្លួន ។
- សេចក្តីណែនាំលេខ ១៣០-០៤អប ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៤ និងសេចក្តីណែនាំទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ ត្រូវចាត់ទុកជានិរាករណ៍ ។

សេចក្តីណែនាំនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ អង្គារ ៦កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩

**អគ្គទេសាភិបាល** (signed: **ជា ចាន់តូ** — as printed: **អគ្គបេឡា ៤** / **ចាំ_យ៉ាង**)

**ចម្លងជូន:**

- គ្រប់អគ្គនាយកដ្ឋាន
  "ដើម្បីជូនជ្រាប"
- នាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា
- គ្រប់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ